ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៥ . សរណន

# សារាចរណែនាំ
## ស្តីពី
## ការពង្រឹងការងារគ្រប់គ្រងវិស័យសកម្មភាពមីន

សកម្មភាពកំចាត់មីន គឺជាគោលដៅអភិវឌ្ឍន៍សហសវត្សទី៩របស់កម្ពុជា ដែលរាជរដ្ឋាភិបាលបានកំណត់យកធ្វើជាអាទិភាពចំបងមួយសំដៅរួមចំណែកនិងជំរុញការអភិវឌ្ឍន៍ប្រទេសជាតិ ពិសេសនៅក្នុងការសម្រេចយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ច។ គោលដៅរបស់រាជរដ្ឋាភិបាលគឺការរំដោះផ្ទៃដីនៃព្រះរាជាណាចក្រកម្ពុជាឲ្យរួចផុតពីការគំរាមកំហែងដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម តាមរយៈការដាក់ចេញនូវផែនការយុទ្ធសាស្រ្ត និងកំណត់ពេលវេលាជាក់លាក់ ក្នុងការបោសសម្អាតតំបន់សង្ស័យថាមានការគម្រាម និងឈានទៅកាត់បន្ថយចំនួនជនរងគ្រោះរហូតដល់កម្រិតសូន្យនៅមុនឆ្នាំ២០២០។ ដើម្បីជំរុញនិងពន្លឿនការអនុវត្តផែនការយុទ្ធសាស្រ្តជាតិ ឈានទៅសំរេចជោគជ័យ រាជរដ្ឋាភិបាលសម្រេចណែនាំដូចខាងក្រោម៖

១. ក្រសួង-ស្ថាប័ន អាជ្ញាធរ អង្គភាព និងភ្នាក់ងារពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាលត្រូវបន្តកិច្ចសហការជិតស្និទ្ធជាមួយអាជ្ញាធរមីនកម្ពុជា ដើម្បីជំរុញការអនុវត្តផែនការសកម្មភាពនៃការបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅតាមតំបន់គោលដៅទាំងអស់ឲ្យសម្រេចបានជោគជ័យ តាមកាលវិភាគនៃផែនការយុទ្ធសាស្រ្តជាតិសកម្មភាពមីន ២០១០-២០១៩ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តសហការ និងវិភាជថវិការផ្តល់អាជ្ញាធរមីនកម្ពុជាឲ្យបានសមស្រប និងទាន់ពេលវេលាទៅតាមដំណាក់កាលនិមួយៗ ដើម្បីគាំទ្ររាល់សកម្មភាពបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមឲ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។

៣. គ្រប់ក្រសួង-ស្ថាប័នដែលអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងអភិវឌ្ឍន៍ដែលតម្រូវឲ្យមានការបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ត្រូវសហការពិគ្រោះយោបល់ជាមួយអាជ្ញាធរមីនកម្ពុជា ដើម្បីកំណត់នូវវិធានការចាំបាច់ និងវិធីសាស្រ្តប្រសើរបំផុតសម្រាប់ដោះស្រាយបញ្ហា និងដើម្បីបញ្ចៀសនូវហានិភ័យនានាដែលអាចកើតមាន។ ការចុះកិច្ចសន្យា ត្រូវធ្វើឡើងតែជាមួយប្រតិបត្តិករដោះមីនដែលមានអាជ្ញាប័ណ្ណពីអាជ្ញាធរមីនកម្ពុជាតែប៉ុណ្ណោះ ដើម្បីលើកកម្ពស់និងធានានូវការគោរពបទបញ្ញត្តិ គុណភាព សុវត្ថិភាព និងស្តង់ដានៃការបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។

៤. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវសហការជិតស្និទ្ធជាមួយអាជ្ញាធរមីនកម្ពុជា ដើម្បីចែកទិន្នន័យស្តីពីការគាំទ្រ និងការផ្តល់សេវាដល់ជនរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចេញពីកំណត់ត្រាទូទៅនៃវិស័យពិការភាពទាំងមូល។

៥. អាជ្ញាធរមីនកម្ពុជាត្រូវបន្តជំរុញល្បឿននៃវឌ្ឍនភាពក្នុងការដឹកនាំការអនុវត្តន៍យុទ្ធសាស្ត្រជាតិសកម្មភាពមីន និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឲ្យសម្រេចបានជោគជ័យ និងត្រូវដាក់ចេញនូវយន្តការ តាមដានត្រួតពិនិត្យ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តន៍យុទ្ធសាស្ត្រជាតិនេះ។ អាជ្ញាធរមីនកម្ពុជា ត្រូវបន្តផ្តល់ជាត្រីវិស័យដល់បណ្តាប្រតិបត្តិករដោះមីនទាំងអស់ ដើម្បីឲ្យប្រតិបត្តិករទាំងនោះអាចយល់ដឹង និងគោរពបានដោយត្រឹមត្រូវតាមគោលការណ៍ណែនាំក្នុងការរៀបចំផែនការបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ព្រមទាំងធានាថាគោលដៅជាយុទ្ធសាស្ត្រទាំងអស់អាចអនុវត្ត និងសម្រេច ទៅបានដោយជោគជ័យ។

៦. ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ សប្បុរសជន និងវិស័យឯកជននានា ត្រូវពិភាក្សាជាមួយអាជ្ញាធរមីននៅពេលជ្រើសរើសប្រតិបត្តិករ និងទីតាំងដែលនឹងត្រូវបោសសម្អាត ដែលការធ្វើដូច្នេះមិនត្រឹមតែនាំឲ្យគម្រោងនានារបស់ខ្លួនដើរស្របទៅតាមផែនការអាទិភាពជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រើប្រាស់ថវិកាបានចំទិសដៅនិងមានប្រសិទ្ធភាពទៀតផង។

៧. បណ្តាក្រុមហ៊ុនអាជីវកម្ម និងអ្នកសាងសង់គម្រោងឯកជនទាំងអស់ដែលមានទីតាំងវិនិយោគស្ថិតនៅក្នុងតំបន់ដែលមានការគំរាម ឬសង្ស័យថាមានគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ត្រូវសហការនិងពិភាក្សាជាមួយអាជ្ញាធរមីនកម្ពុជា អាជ្ញាធរខេត្ត ឬ អង្គភាពធ្វើផែនការសកម្មភាពមីនខេត្តជាដើម ដើម្បីកំណត់អត្តសញ្ញាណពិតប្រាកដនៃទីតាំងដែលមានការគំរាម និងចាំបាច់ត្រូវបោសសម្អាតជាមុន មុននឹងចាប់ផ្តើមអនុវត្តការសាងសង់ ឬធ្វើសកម្មភាពនានារបស់ខ្លួន ដោយត្រូវជ្រើសរើសប្រតិបត្តិករបោសសម្អាតដែលមានអាជ្ញាប័ណ្ណ ពីអាជ្ញាធរមីនកម្ពុជា។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន អាជ្ញាធរ ប្រតិបត្តិករបោសសម្អាតមីន ក្រុមហ៊ុនអាជីវកម្ម និងអង្គការពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួងស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-រាជធានី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ